# ការប្ដឹងតវ៉ាខាងទូរទស្សន៍និងវិទ្យុផ្សាយសំឡេង: មគ្គុទ្ទេសមួយសំរាប់ទូរទស្សនិកជននិងអ្នកស្ដាប់វិទ្យុផ្សាយសំឡេង

www.bsa.govt.nz

**បើអ្នកមានការខ្វល់ខ្វាយបារម្ភអំពីមាតិកានៃកម្មវិធីទូរទស្សន៍និងវិទ្យុផ្សាយសំឡេង ច្បាប់អនុញ្ញាតឱ្យអ្នកប្ដឹងតវ៉ាទៅគេបានហើយធ្វើឱ្យប្រាកដថា ការតវ៉ារបស់អ្នកត្រូវគេយកទៅគិតគូរដោយប្រាកដប្រជា ។ ដោយប្ដឹងតវ៉ាជាផ្លូវការ ទូរទស្សនិកជន និងអ្នកស្ដាប់វិទ្យុផ្សាយសំឡេងអាចជួយថែទាំរក្សាបទដ្ឋាននៃការផ្សាយទូរទស្សន៍និងវិទ្យុសំឡេងឱ្យបានល្អប្រសើរ ។**

មគ្គុទ្ទេសនេះពន្យល់អំពីរបៀបសំរាប់ប្ដឹងតវ៉ាជាផ្លូវការ និងមុខនាទីរបស់អាជ្ញាធរបទដ្ឋានការផ្សាយ ( ហៅកាត់ថា "ប៊ីអេសអេ" ) (the Broadcasting Standards Authority (the BSA) ក្នុងការអង្កេតនិងពិនិត្យដោយហ្មត់ចត់ឡើងវិញនូវបណ្ដឹងតវ៉ាដែលបានធ្វើទៅអ្នកផ្សាយទូរទស្សន៍និងវិទ្យុផ្សាយសំឡេង ។

### តើខ្ញុំអាចប្ដឹងតវ៉ាអំពីអ្វីបាន?

អ្នកអាចធ្វើការប្ដឹងតវ៉ាជាលក្ខណៈផ្លូវការអំពីកម្មវិធីណាដែលអ្នកយល់ថាបានបំពានលើបទដ្ឋាននៃការផ្សាយខាងទូរទស្សន៍នឹងវិទ្យុ ។ កម្មវិធី (Programme) គឺអ្វីមួយដែលបានផ្សាយតាមទូរទស្សន៍ឬវិទ្យុ រួមទាំងវគ្គផ្សាយពាណិជ្ជកម្មសំរាប់កម្មវិធីនោះផង ។ អ្នកក៏អាចប្ដឹងតវ៉ាអំពីការផ្សាយឃោសនាផ្នែកនយោបាយដែលមានមុនការបោះឆ្នោតរើសសមាជិករដ្ឋសភាផងដែរ ។

សូមកត់ចំណាំថាបណ្ដឹងតវ៉ាអំពី **ការផ្សាយពាណិជ្ជកម្ម** ត្រូវធ្វើទៅអាជ្ញាធរបទដ្ឋានការផ្សាយពាណិជ្ជកម្ម (the Advertising Standards Authority), PO Box 10 675, Wellington អ៊ីមែល asa@asa.co.nz វិបសាយ www.asa.co.nz

### តើអ្វីទៅជា "បទដ្ឋានការផ្សាយទូរទស្សន៍និងវិទ្យុសំឡេង"?

បទដ្ឋានការផ្សាយសំរាប់កម្មវិធីទូរទស្សន៍និងវិទ្យុផ្សាយសំឡេងរួមមានទាំង:

- មាននិស្ស័យល្អវិចិត្រនិងភាពសមរម្យត្រឹមត្រូវតាមវិន័យនានា
- ច្បាប់និងបញ្ញត្តិ
- ភាពមិនផ្សៀងផ្អងទៅម្ខាង១
- សុច្ចរិតយុត្តិធមិ
- ការប្រកាន់រើសអើង

- ភាពទៀងត្រង់ត្រឹមត្រូវ
- ភាពដាច់ដោយឡែកពីគេនៃឯកត្តជន
- ការការពារក្មេង
- ហឹង្សា
- ការផ្សាយលក់គ្រឿងស្រវឹង
- ការចាត់កម្មវិធីជាថ្នាក់-ផ្នែក
- ព័ត៌មានអំពីកម្មវិធី ។

មគ្គុទ្ទេសពិស្តារដែលពន្យល់អំពីបទដ្ឋានការផ្សាយគឺមាននៅក្នុង ក្រមអនុវត្តិខាងការផ្សាយវិទ្យុនិងទូរទស្សន៍ (Codes of Broadcasting Practices) ដែលអាចមើលបាននៅ **www.bsa.govt.nz** ឬតាមទូរស័ព្ទ ឬសរសេរទៅ ប៊ីអេសអេ ។

## តើខ្ញុំត្រូវធ្វើយ៉ាងណាដើម្បីធ្វើបណ្តឹងតវ៉ាជាផ្លូវការ?

បើអ្នកចង់ធ្វើបណ្តឹងតវ៉ាអំពីការបំពានលើបទដ្ឋាននៃការផ្សាយខាងទូរទស្សន៍នឹងវិទ្យុ, ជាដំបូងអ្នកត្រូវសរសេរទៅអ្នកផ្សាយនោះតែម្តង ។ សូមផ្ញើសំបុត្រប្តឹងតវ៉ារបស់អ្នកទៅនាយកក្រុមហ៊ុនផ្សាយ (Chief Executive) នោះ លើកលែងតែករណីមួយ គឺការប្តឹងតវ៉ាអំពីការបំពានលើភាពដាច់ដោយឡែកពីគេ (breach of privacy) ។ ក្នុងករណីយនេះ ត្រូវផ្ញើបណ្តឹងទៅចាងហ្វាងខាងច្បាប់នៃប៊ីអេសអេ (BSA’s legal manager) ផ្ទាល់តែម្តង ។ អ្នកអាចដាក់ពាក្យប្តឹងតវ៉ាដោយប្រើគំរូ (form) ដែលមាននៅក្នុងវ៉ិបសាយ www.bsa.govt.nz ឬផ្ញើអ៊ីមែលទៅអ្នកផ្សាយនោះ ឬតាមសំបុត្រ ។

## បណ្តឹងតវ៉ាជាផ្លូវការត្រូវ:

- សរសេរជាលាយល័ក្ខអក្សរ (ហើយមានរួមទាំងពាក្យ "បណ្តឹងតវ៉ាជាផ្លូវការ" (formal complaint))

- បានទទួលដោយអ្នកផ្សាយ(ឬប៊ីអេសអេ ក្នុងករណីដែលបណ្តឹងតវ៉ានោះទាក់ទងទៅភាពដោយឡែកពីគេ) ក្នុងរយ: ២០ ថ្ងៃ-ថ្ងៃធ្វើការ, ចាប់ពីថ្ងៃនៃការផ្សាយអ្វីដែលអ្នកប្តឹងតវ៉ានោះ ("ថ្ងៃធ្វើការ" មិនរួមបញ្ចូលថ្ងៃចុងអាទិត្យ, ថ្ងៃឈប់សំរាកសាធារណ: និងថ្ងៃចាប់ពីថ្ងៃបុណ្យណូអែលរហូតដល់ថ្ងៃទី១៥មករាទេ)

- មានរួមបញ្ចូលឈ្មោះកម្មវិធីនោះ, ប៉ុស្តឬស្ថានីយដែលផ្សាយ និងថ្ងៃនិងម៉ោងពេលដែលផ្សាយ

- អធិប្បាយលើកឡើងនូវបទដ្ឋាននៃការផ្សាយណាដែលអ្នកយល់ថាដែលត្រូវបានបំពានលើ, បើតាមអ្នកយល់ឃើញ

- អធិប្បាយលើកឡើងយ៉ាងច្បាស់អំពីហេតុអ្វីដែលអ្នកយល់ថាកម្មវិធីនោះបំពានលើបទដ្ឋានមួយនោះ ឬបទដ្ឋានទាំងនោះ ។

ពេលលើកឡើងយ៉ាងច្បាស់អំពីអ្វីដែលធ្វើឱ្យអ្នកយល់ថាកម្មវិធីមួយបានបំពានលើបទដ្ឋានណាមួយ វាជាការមានប្រយោជន៍ណាស់ដែលអ្នកលើកឧទាហរណ៍ពិតជាក់ស្តែងមួយឡើង ។ ឧទាហរណ៍ ដកស្រង់សំដីដែលអ្នកបានយល់ថាហួសហេតុ, អធិប្បាយអំពីឈុតដែលអ្នកយល់ឃើញថាមាននិស្ស័យមិនល្អ, ឬបញ្ជាក់សេចក្តីអធិប្បាយណាដែលអ្នកបានយល់ថាមិនសមហេតុផល ឬលំអៀង ។

**តើពេលណាខ្ញុំអាចបញ្ជូនបណ្តឹងតវ៉ាមួយទៅប៊ីអេសអេបាន?**

ច្បាប់ *ស្តីអំពីការផ្សាយខាងទូទស្សន៍ឆ្នាំ១៩៨៩* (The Broadcasting Act 1989) តម្រូវអ្នកផ្សាយឆ្លើយតបទៅបណ្តឹងតវ៉ារបស់អ្នកក្នុងរយៈពេល២០ថ្ងៃ-ថ្ងៃធ្វើការក្រោយពីបានទទួលបណ្តឹងនោះ ។

បើអ្នកមិនពេញចិត្តនឹងសេចក្តីឆ្លើយតបពីអ្នកផ្សាយនោះទេ, នោះអ្នកមានពេល២០ថ្ងៃ-ថ្ងៃធ្វើការ ដើម្បីបញ្ជូនបណ្តឹងតវ៉ានោះទៅប៊ីអេសអេដើម្បីឱ្យមានការអង្កេតនិងពិនិត្យដោយហ្មត់ចត់ឡើងវិញដោយមនុស្សផ្សេងទៀត ។

បើអ្នកផ្សាយមិនឆ្លើយតបមកវិញក្នុរយៈពេល២០ថ្ងៃ-ថ្ងៃធ្វើការទេ, អ្នកមានពេលរហូតដល់៦០ថ្ងៃ-ថ្ងៃធ្វើការ ចាប់ពីថ្ងៃនៃការផ្សាយដើម្បីបញ្ជូនការប្តឹងតវ៉ានោះទៅប៊ីអេសអេ ។

**តើមានអ្វីកើតឡេងពេលណាខ្ញុំបញ្ជូនបណ្តឹងតវ៉ាមួយទៅប៊ីអេសអេ?**

ប៊ីអេសអេនឹងឱ្យដំណឹងទៅអ្នកផ្សាយឱ្យបានដឹងអំពីបណ្តឹងតវ៉ាមួយដែលបានបញ្ជូនទៅឱ្យដោះស្រាយ ហើយផ្ញើច្បាប់ចម្លងមួយច្បាប់នៃការប្តឹងទៅដល់អ្នកផ្សាយ ហើយអញ្ជើញអ្នកផ្សាយនោះឱ្យឆ្លើយតបវិញ ។

ប៊ីអេសអេផ្ញើច្បាប់ចម្លងនៃចម្លើយរបស់អ្នកផ្សាយមួយច្បាប់មកអ្នក ។ បើអ្នកផ្សាយនោះបញ្ចេញមតិបន្ថែមទៅប៊ីអេសអេ អ្នកនឹងត្រូវគេអញ្ជើញឱ្យឆ្លើយតបជាលើកចុងក្រោយបង្អស់ ទៅមតិនោះវិញ ។

សមាជិកក្រុមប្រឹក្សាទាំងបួននៃប៊ីអេសអេ ពិចារណាគិតថ្លឹងថ្លែងលើពាក្យបណ្តឹងរបស់អ្នកនៅក្នុងអង្គប្រជុំក្រុមប្រឹក្សាមួយ ។ ក្រុមប្រឹក្សាពិនិត្យលើភស្តុតាងទាំងអស់, ជជែកពិភាក្សាបណ្តឹងតវ៉ារបស់អ្នក, ហើយសំរេចថាតើគាំទ្រយល់ព្រមជាមួយឬមិនគាំទ្របណ្តឹងតវ៉ានោះ ។

ជាធម្មតាកិច្ចប្រតិបត្តនៃប៊ីអេសអេគឺពិចារណាសេចក្តីរាយការណ៍របស់អ្នកប្តឹងតវ៉ានិងអ្នកផ្សាយ ប៉ុន្តែគេក៏អាចចាត់ចែងធ្វើជាសវនាការ បើគេយល់ថា នេះជាការចាំបាច់ ។

សេចក្ដីសំរេចនៃក្រសួងប៉ុអេសអេជាលាយលក្ខអក្សត្រូវគេផ្ញើទៅអ្នក និងអ្នកផ្សាយ ។ គេក៏ផ្ញើសេចក្ដីសំរេចនោះទៅក្រុមផ្សាយព័តិមាននិងអ្នកជាវទៅប៉ុអេសអេ, ព្រមទាំងដាក់ផ្សាយនៅក្នុងវ៉ិបសាយរបស់ប៉ុអេសផង ។

ពេលដោះស្រាយបណ្ដឹងតវ៉ា ដែលមិនទាន់មានភ័ស្ដុតាង អំពីការបំពានលើភាពដាច់ដោយឡែកពីគេប៉ុអេសអេតែងមានសណ្ដោសដល់សំនើរមិនឱ្យបញ្ចេញឈ្មោះអ្នកផ្ដើម ។

បើប៉ុអេសអេយល់ស្របជាមួយបណ្ដឹងតវ៉ា, គេអាចប្រហែលជា:

- ចេញបញ្ជាឱ្យអ្នកផ្សាយបោះពុម្ពផ្សាយរបាយការណ៏, ឧទាហរណ៍ដូចជាសេចក្ដីកែតម្រូវ ឬសេចក្ដីសង្ខេបនៃសេចក្ដីសំរេច
- ចេញបញ្ជាឱ្យអ្នកផ្សាយបង់ថ្លៃដែលទាក់ទងការសំរេចសេចក្ដីទៅរដ្ឋរហូតដល់៥០០០ដុល្លារ
- ចេញបញ្ជាឱ្យអ្នកផ្សាយសងជម្ងឺចិត្ត រហូតដល់៥០០០ដុល្លារ ទៅមនុស្សដែលអ្នកផ្សាយបានបំពានលើភាពដាច់ដោយឡែកពីគេ

ក្នុងករណើយយ៉ាងធ្ងន់បំផុត ប៉ុអេសអេអាចចេញបញ្ជាបញ្ឈប់អ្នកផ្សាយមិនឱ្យផ្សាយអ្វីៗទាំងអស់ ឬបញ្ឈប់មិនឱ្យផ្សាយពាណិជ្ជកម្មមួយរយៈរហូតដល់២៤ម៉ោង ។

គេអាចប្ដឹងឧទ្ធរណ៍សេចក្ដីសំរេចនៃប៉ុអេសអេទៅហាយខត៍ ( តុលាការ ) (High Court)បាន ។ ប្រសិនបើអ្នកផ្សាយប្ដឹងឧទ្ធរណ៍សេចក្ដីសំរេចនោះទៅហាយខត៍ គេនឹងបញ្ចេញឈ្មោះអ្នកដើមបណ្ដឹងជាភាគីម្ខាង, តែគេអាចសំរេចចិត្តមិនចូលរួមក្នុងវិធីកាត់ក្ដីនៃតុលាការនេះបាន ។

**សេចក្តីបញ្ជាក់**

បណ្ដឹងតវ៉ាជាផ្លូវការដែលសរសេរជាលាយលក្ខអក្សត្រូវសរសេរជាភាសាអង់គ្លេស ឬភាសារផ្លូវការមួយទៀតនៃប្រទេសនូហ្ស៊ីលែន, ក៏ប៉ុន្ដែអាចអំពីមាតិការកម្មវិធីដែលផ្សាយជាភាសាណាក៏បាន ។ ពាក្យបណ្ដឹងជាផ្លូវការអាចធ្វើរក្នុងនាមផ្ទាល់ខ្លួន ឬជាក្រុមដោយមានតំណាងម្នាក់ដូចជាសមាជិកសមាគមឬអ្នកច្បាប់ឬក៏អ្នកជួយគាំទ្រ ។

**អស័យដ្ឋាន**

សូមការខ្ចងសំបុត្របណ្ដឹងតវ៉ាជាផ្លូវការទៅ Chief Executive ( នាយក ) ក្រុមហ៊ុនផ្សាយកម្មវិធីនោះគឺ:

**ទូរទស្សន៍**

TVNZ
PO Box 3819
AUCKLAND 1141
ទូរស័ព្ទ: (09) 916 7000
ទូរសារ: (09) 916 6864
www.tvnz.co.nz

TV3 and TV4
TVWorks
Private Bag 92 624
AUCKLAND 1150
ទូរស័ព្ទ: (09) 377 9730
ទូរសារ: (09) 366 5999
ទូរស័ព្ទមិនបាច់បង់ប្រាក់: 0800 888 4733
www.tv3.co.nz
standardscommittee@mediaworks.co.nz

Maori Television
PO Box 113-017
Newmarket
AUCKLAND 1149
ទូរស័ព្ទ: (09) 539 7000
ទូរសារ: (09) 539 7199
www.maoritelevision.com

Prime Television
PO Box 9059
Newmarket
AUCKLAND 1149
ទូរស័ព្ទ: (09) 579 9999
ទូរសារ: (09) 579 8355
ទូរស័ព្ទមិនបាច់បង់ប្រាក់: 0800 759 759
www.primetv.co.nz

Sky Television
PO Box 9059
Newmarket
AUCKLAND 1149
ទូរស័ព្ទ: (09) 579 9999
ទូរសារ: (09) 579 8355
ទូរស័ព្ទមិនបាច់បង់ប្រាក់: 0800 759 759
www.skytvnz.co.nz

## វិទ្យុ

ចំពោះការផ្សាយនៃ Radio New Zealand National (វិទ្យុជាតិ នូហ្ស៊ីលែន) ឬ Radio New Zealand Concert (វិទ្យុនូហ្ស៊ីលែន ខាងប្រគុំភ្លេង), ត្រូវផ្ញើបណ្តឹងតវ៉ាជាផ្លូវការទៅ:

Radio New Zealand
PO Box 123
WELLINGTON 6140
ទូរស័ព្ទ: (04) 474 1999
ទូរសារ: (04) 474 1459
www.radionz.co.nz

ចំពោះអស័យដ្ឋានរបស់ស្ថានីយឯកជនសូមរកមើលដោយខ្លួនឯងតែម្តង ឬអ្នកអាចសុំបានពី:

Radio Broadcasters Assn
PO Box 3762
AUCKLAND 1140
ទូរស័ព្ទ: (09) 378 0788
ទូរសារ: (09) 378 8180
www.rba.co.nz

ទំនាក់ទំនងទៅក្រុមផ្សាយព័ត៌មានឯទៀតមាននៅ **www.bsa.govt.nz**

**តារាងត្រួតពិនិត្យលក្ខណៈបណ្តឹង**

☐ តើអ្នកមានបានសរសេរបណ្តឹងនេះជាលាយល័ក្ខអក្សរទៅនាយករបស់ក្រុមហ៊ុនផ្សាយនោះហើយឬនៅ?

☐ តើអ្នកផ្សាយនឹងអាចទទួលបណ្តឹងតវ៉ាជាផ្លូវការក្នុងរយៈ២០ថ្ងៃក្រោយពីថ្ងៃដែលគេផ្សាយទេ?

☐ តើបណ្តឹងតវ៉ាជាផ្លូវការមានរួមទាំងៈ

- ○ ឈ្មោះកម្មវិធីដែលអ្នកចង់ប្តឹងតវ៉ា?
- ○ ប៉ុស្ត ឬស្ថានីយដែលផ្សាយ?
- ○ ថ្ងៃនិងម៉ោងដែលផ្សាយ?

☐ តើអ្នកបានលើកឡើងយ៉ាងច្បាស់ថាតើបទដ្ឋានមួយណា ឬបទដ្ឋានទាំងអស់ណាដែលអ្នកយល់ថាត្រូវបានបំពាន, និង តើដោយហេតុអ្វីដែរ?

☐ បើអ្នកប្តឹងតវ៉ាអំពីការបំពានលើ **ភាពដាច់ដោយឡែកពីគេ**, តើអ្នកបានផ្ញើទៅបេអេសអេក្នុងកំឡុង២០ថ្ងៃ-ថ្ងៃធ្វើការ ក្រោយពីថ្ងៃដែលគេផ្សាយកម្មវិធីនោះទេ?

☐ បើអ្នកមិនពេញចិត្តជាមួយចម្លើយរបស់អ្នកផ្សាយទេ, តើអ្នកបានបញ្ជូនបណ្តឹងតវ៉ានោះឡើងទៅ**បេអេសអេ**ដើម្បី ឱ្យគេធ្វើការអង្កេតដោះស្រាយនិងសើរើពិនិត្យឡើងវិញក្នុងរយៈ២០ថ្ងៃក្រោយពីថ្ងៃដែលទទួលចម្លើយពីអ្នកផ្សាយ?

☐ បើអ្នកផ្សាយមិនឆ្លើយតបមកបណ្តឹងតវ៉ាអ្នកក្នុងរយៈ២០ថ្ងៃ, តើអ្នកបានបញ្ជូនបណ្តឹងតវ៉ានោះឡើងទៅ**បេអេសអេ**ដើម្បីឱ្យគេធ្វើការអង្កេតដោះស្រាយនិងសើរើពិនិត្យឡើងវិញក្នុងរយៈ៦០ថ្ងៃក្រោយពីថ្ងៃដែលដែលគេផ្សាយកម្មវិធីនោះ?

Broadcasting Standards Authority

Level 2, NZ Lotteries Commission Building
54-56 Cambridge Terrace
PO Box 9213, Wellington 6141

ទូរស័ព្ទ: (04) 382 9508

ទូរសារ: (04) 382 9543

ទូរស័ព្ទមិនបាច់បង់ប្រាក់: 0800 366 996

អ៊ីមែល: info@bsa.govt.nz